# បទបង្ហាញអនឡាញ
# របៀបសម្គាល់ ដំណឹងក្លែងក្លាយ លើបណ្តាញផ្សព្វផ្សាយសង្គម

## សេចក្តីសង្ខេប

**មជ្ឈមណ្ឌលខេមរសិក្សា** មានក្តីសោមនស្សស្វាគមន៍ **កញ្ញា នូវ ពៅលក្ខិណា** ដែលជាអ្នកជំនាញផ្នែកសារព័ត៌មាន មកចូលរួមធ្វើបទបង្ហាញស្តីអំពី «**របៀបសម្គាល់ ដំណឹងក្លែងក្លាយ នៅលើបណ្តាញផ្សព្វផ្សាយសង្គម**» ជាភាសាខ្មែរ និងអាចចូលរួមបានជាសាធារណៈ។ នាពេលបច្ចុប្បន្ននេះ អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ មានសារៈសំខាន់ជាងពេលណាៗទាំងអស់ ខណៈដែលព័ត៌មានគ្រប់ប្រភេទកំពុងត្រូវបានចែកចាយយ៉ាងទូលំទូលាយ និងឆាប់រហ័សនៅលើប្រព័ន្ធអ៊ិនធឺណិត។ ចំណងជើង អត្ថបទ និងមាតិកាផ្សេងៗទៀត ដែលត្រូវបានផ្សព្វផ្សាយនៅលើបណ្តាញផ្សព្វផ្សាយសង្គមជារៀងរាល់ថ្ងៃ មិនមែនសុទ្ធតែអាចជឿទុកចិត្តបាននោះទេ ដែលជាលទ្ធផលមានដំណឹងក្លែងក្លាយនៅលាយឡំគ្នាដែលយើងបានឃើញ។ ខណៈពេលដែលអ្នកសារព័ត៌មានអាជីពកំពុងស្ថិតនៅជួរមុខខិតខំត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ព័ត៌មានមុនពេលចេញផ្សាយ អ្នកប្រើប្រាស់បណ្តាញសង្គមឆ្លាតវៃត្រូវសិក្សាដើម្បីក្លាយខ្លួនទៅជា ទស្សនិកជនដែលមានអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ ជាមួយសមត្ថភាពអាចសម្គាល់ «ដំណឹងក្លែងក្លាយ» បាន។

## ប្រវត្តិរូបសង្ខេប

**វាគ្មិនៈ កញ្ញា នូវ ពៅលក្ខិណា** ជាគ្រូបង្រៀនមុខវិជ្ជា សារព័ត៌មានអនឡាញ និងពហុប្រព័ន្ធផ្សព្វផ្សាយ នៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ គាត់បានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកសារព័ត៌មាន ពី University of Hong Kong នៅឆ្នាំ២០១៧ និងសញ្ញាបត្រថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០១៣។ គាត់គឺជាអ្នកសារព័ត៌មានដែលមានចំណាប់អារម្មណ៍ខ្លាំងក្នុងការអភិវឌ្ឍវិស័យសារព័ត៌មានឌីជីថលនៅក្នុងប្រទេសកម្ពុជា។ តាមរយៈការបំពេញការងារ គាត់បានចូលរួមបង្កើតគម្រោងផ្សព្វផ្សាយបែបឌីជីថលជាច្រើន ដែលរួមមាន គម្រោងទីចងចាំ ជាកម្មវិធីទូរស័ព្ទនិងគេហទំព័រដែលរៀបរាប់រឿងរ៉ាវនៃទីតាំងសំខាន់ៗក្នុងរបបខ្មែរក្រហម បង្កើតឡើងដោយ ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍។ ក្នុងពេលបច្ចុប្បន្ន គាត់ក៏ជានិពន្ធនាយក សាព័ត៌មាន Focus-ត្រៀមខ្លួនសម្រាប់ថ្ងៃស្អែក ជាសហ

គ្រាសសង្គមមួយ ដែលបង្កើតមាតិកាព័ត៌មាន ដើម្បីជំរុញឱ្យមានការពិភាក្សា ពីសំណាក់បុគ្គលដែលមានតួនាទីជាអ្នកផ្លាស់ប្តូរដ៏សំខាន់មួយនាពេលថ្ងៃអនាគត។

**អ្នកសម្របសម្រួល៖ កញ្ញា ស៊្លួង សាម៉ីឌី** ប្រធានកម្មវិធី នៃមជ្ឈមណ្ឌលខេមរសិក្សា។